ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ORDRE DES AVOCATS DU ROYAUME DU CAMBODGE


**ប្រធានគណៈមេធាវី**

មេធាវី លី ច័ន្ទតុលា

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ចូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុច ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណាថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុតក្រ្គ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុត កែវសុត្ថា


លេខ ៤៩៤ /សសគម/២១

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃមហាសន្និបាតលើកទី២៦ និងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី១០

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ច័ន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១



អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

## ស ម្រេ ច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ៈ គោលបំណង**

សេចក្ដីសម្រេចនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការរៀបចំមហាសន្និបាតលើកទី២៦ របស់គណៈមេធាវី និងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០ ក្នុងស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងគោលបំណងបង្ការនិងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ដល់សមាជិក-សមាជិកាគណៈមេធាវី។

**ប្រការ២ ៈ វិសាលភាព**

សេចក្ដីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះការរៀបចំមហាសន្និបាតលើកទី២៦ របស់គណៈមេធាវី និងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០។

## ជំពូកទី២
## មហាសន្និបាតរបស់គណៈមេធាវី

**ប្រការ៣ ៈ ការរៀបចំមហាសន្និបាតរបស់គណៈមេធាវី**

មហាសន្និបាតលើកទី២៦ របស់គណៈមេធាវី ត្រូវរៀបចំចំនួន៣(បី)ថ្ងៃ គឺចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១។ មហាសន្និបាតនេះប្រារព្ធឡើងនៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ៈ ការប្រព្រឹត្តទៅនៃមហាសន្និបាតរបស់គណៈមេធាវី**

មហាសន្និបាតលើកទី២៦ នេះ ត្រូវធ្វើតាមការប្រជុំតាមប្រព័ន្ធ ZOOM Meeting។ មហាសន្និបាតលើកទី២៦ នេះ ប្រព្រឹត្តទៅក្រោមអធិបតីប្រធានគណៈមេធាវី និងមានសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឬតំណាង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញឬតំណាងចូលរួមផ្ទាល់ ដោយយកទីស្នាក់ការគណៈមេធាវីធ្វើជាទីតាំងកណ្ដាលសម្រាប់ប្រារព្ធពិធីនៃមហាសន្និបាត។ ចំពោះសមាជិក-សមាជិកាគណៈមេធាវី ត្រូវចូលរួមប្រជុំតាមប្រព័ន្ធ ZOOM Meeting តាមរយៈតំណភ្ជាប់ដែលផ្ដល់ជូនដោយគណៈមេធាវី ។

បែបបទលម្អិតនៃការប្រារព្ធអង្គមហាសន្និបាតលើកទី២៦ នេះ ត្រូវកំណត់ក្នុងសេចក្ដីណែនាំរបស់ប្រធានគណៈមេធាវី។

**ប្រការ៥ ៈ របៀបវារៈនៃមហាសន្និបាតរបស់គណៈមេធាវី**

មហាសន្និបាតលើកទី២៦ របស់គណៈមេធាវី ត្រូវប្រព្រឹត្តទៅស្របតាមរបៀបវារៈដូចខាងក្រោមៈ

- សុន្ទរកថាបើកមហាសន្និបាតដោយប្រធានគណៈមេធាវី
- ជូនរបាយការណ៍សកម្មភាពនិងហិរញ្ញវត្ថុរបស់គណៈមេធាវីក្នុងរយៈពេលមួយឆ្នាំកន្លងមក
- បោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០

- ប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០
- មតិបូកសរុបនិងបិទមហាសន្និបាតដោយប្រធានគណៈមេធាវី។

ប្រធានគណៈមេធាវី អាចបន្ថែមរបៀបវារៈមួយចំនួន តាមការចាំបាច់ជាក់ស្តែង។

របៀបវារៈនេះ ត្រូវជូនដំណឹងដល់សមាជិក-សមាជិកាគណៈមេធាវីយ៉ាងតិច ១(មួយ)ខែមុនមហាសន្និបាត តាមគ្រប់មធ្យោបាយ។

សមាជិក-សមាជិកាគណៈមេធាវី អាចលើកសំណូមពរឬដាក់ញត្តិជាលាយលក្ខណ៍អក្សរមកក្រុមប្រឹក្សាគណៈមេធាវី ដែលត្រូវដោះស្រាយក្នុងរយៈពេល ៣(បី)ខែ។

## ជំពូកទី៣
## ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី

### ប្រការ៦ .. ការរៀបចំការបោះឆ្នោត

ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០ ត្រូវប្រព្រឹត្តទៅជាសម្ងាត់ និងជាឯកនាម។ ការបោះឆ្នោតនេះ ត្រូវប្រព្រឹត្តទៅនៅក្នុងរយៈពេលនៃការប្រារព្ធមហាសន្និបាតលើកទី២៦ របស់គណៈមេធាវី ដោយអ្នកបោះឆ្នោតត្រូវមកបោះផ្ទាល់នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

គណៈមេធាវី ត្រូវរៀបចំឱ្យមានការិយាល័យបោះឆ្នោតយ៉ាងតិចចំនួន ១៥(ដប់ប្រាំ) ការិយាល័យ ដោយត្រូវគោរពនិងអនុវត្តតាមវិធានការរដ្ឋបាល វិធានការសុខាភិបាល និងវិធានការអនាម័យ ដូចជា រក្សាគម្លាតសុវត្ថិភាព ពាក់ម៉ាស់ លាងសម្អាតដៃជាមួយអាល់កុលជាដើម។

បែបបទលម្អិតមានកំណត់ក្នុងបទបញ្ជានិងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០ ដែលសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

### ប្រការ៧ .. បេក្ខភាពឈរឈ្មោះបោះឆ្នោត

បេក្ខភាពឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- ជាមេធាវីពេញសិទ្ធិចាប់ពី ២(ពីរ)ឆ្នាំឡើងទៅ ដោយគិតចាប់ពីថ្ងៃចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី រហូតដល់ថ្ងៃចាប់ផ្តើមបោះឆ្នោត(ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១)
- ជាមេធាវីមានសិទ្ធិបោះឆ្នោត
- គតដែលបាត់បង់សិទ្ធិបោះឆ្នោត ដោយទណ្ឌកម្មវិន័យណាមួយ។

### ប្រការ៨ .. អ្នកបោះឆ្នោត

មេធាវីដែលមានសិទ្ធិបោះឆ្នោតមាន៖

- មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈមេធាវី
- មេធាវីពេញសិទ្ធិដែលស្នើសុំមិនប្រកបវិជ្ជាជីវៈមេធាវី

- មេធាវីពេញសិទ្ធិដែលត្រូវបានហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈមេធាវី តែមិនត្រូវបានទទួលទណ្ឌកម្មដកសិទ្ធិបោះឆ្នោត។

**ប្រការ៩ .. ការកោះអញ្ជើញចូលរួមការបោះឆ្នោត**

មេធាវីដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ត្រូវបានកោះអញ្ជើញ ១(មួយ)ខែមុនថ្ងៃបោះឆ្នោត តាមគ្រប់មធ្យោបាយ។

**ប្រការ១០ .. ដំណើរការនៃការបោះឆ្នោត**

ការបោះឆ្នោតនឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានមេធាវីពេញសិទ្ធិចំនួនលើសពីពាក់កណ្តាល មានវត្តមានតាមប្រព័ន្ធ ZOOM Meeting នៅក្នុងកិច្ចប្រជុំនៃមហាសន្និបាតលើកទី២៦ ។ ក្រុមការងារស្រង់វត្តមាន ត្រូវកត់ត្រាជាប្រចាំនូវវត្តមានរបស់សមាជិកដែលបានចូលរួមប្រជុំតាមប្រព័ន្ធ ZOOM Meeting ហើយត្រូវរាយការណ៍អំពីវត្តមាននេះជូនប្រធានគណៈមេធាវីនិងប្រធានគណៈកម្មការបោះឆ្នោតនៅមុនពេលចាប់ផ្តើមបោះឆ្នោត។

ការិយាល័យបោះឆ្នោតត្រូវស្ថិតនៅក្រោមអធិបតីភាព របស់មេធាវីដែលត្រូវបានសម្រេចជ្រើសតាំងជាប្រធានគណៈកម្មការបោះឆ្នោត ដោយក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមួយត្រូវបានបង្កើតឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

គណៈកម្មការបោះឆ្នោតមានតួនាទីរៀបចំដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០។

សមាជិកគណៈកម្មការបោះឆ្នោតត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាគណៈមេធាវី ក្នុងចំណោមមេធាវីពេញសិទ្ធិ មេធាវីកម្មសិក្សា សិស្សមេធាវី និងបុគ្គលិកគណៈមេធាវី ដែលស្ម័គ្រចិត្តដាក់ពាក្យសុំចូលរួមជួយបំពេញកិច្ចការនេះ។

គណៈកម្មការបោះឆ្នោតជាគណៈកម្មការចំពោះកិច្ច ដែលត្រូវចប់ភារកិច្ច និងរំលាយដោយស្វ័យប្រវត្តិក្រោយពីការរាប់សន្លឹកឆ្នោតនិងការប្រកាសលទ្ធផលនៃការបោះឆ្នោតចប់សព្វគ្រប់។

ប្រធានគណៈមេធាវីឬតំណាងប្រធានគណៈមេធាវីអារកាត់លើគ្រប់ឧបសគ្គ ដែលអាចកើតមាននៅពេលបោះឆ្នោត ឬនៅពេលរាប់សន្លឹកឆ្នោត។

នៅពេលចូលទៅកាន់ការិយាល័យបោះឆ្នោត មេធាវីដែលមានសិទ្ធិបោះឆ្នោតត្រូវពាក់អាវវិជ្ជាជីវៈមេធាវី ឬអាវសម្រាប់ពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យនានារបស់គណៈមេធាវី និងបង្ហាញប័ណ្ណសម្គាល់មេធាវីឬលិខិតបញ្ជាក់អត្តសញ្ញាណ ដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត។

គ្រប់ការបោះឆ្នោតណាដែលដៅទៅលើជនដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ ត្រូវចាត់ទុកជាមោឃៈ។ ការបោះឆ្នោតដោយក្រដាសសលាតឬមោឃៈត្រូវរាប់ទុកដោយឡែក និងមិនត្រូវបានលើកយកមករាប់បញ្ចូលដើម្បីគិតរកសំឡេងភាគច្រើនឡើយ។

**ប្រការ១១ .. ការរាប់សន្លឹកឆ្នោត**

នៅតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោត នៅចំពោះមុខបេក្ខជននិងអ្នកសង្កេតការណ៍របស់បេក្ខជន ប្រសិនបើមាន។

**ប្រការ១២ ៈ ការប្រកាសលទ្ធផលនៃការបោះឆ្នោត**

លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០ ត្រូវប្រកាសដោយប្រធានគណៈមេធាវី បន្ទាប់ពីការរាប់សន្លឹកឆ្នោតភ្លាម។ លទ្ធផលនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។ ក្រុមប្រឹក្សាគណៈមេធាវីនៅក្នុងតំណែង ត្រូវទទួលដឹងឮលទ្ធផលនេះនៅក្នុងសម័យប្រជុំរបស់ខ្លួនជាបន្ទាប់។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១៣ ៈ និរាករណ៍**

សេចក្ដីសម្រេចលេខ៤៨៨/សសគម/២១ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមហាសន្និបាតលើកទី២៦ និងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ១៤ ៈ ការអនុវត្ត**

អគ្គលេខាធិការគណៈមេធាវី ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍១៣កើតខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២២ខែកក្កដា ឆ្នាំ២០២១

**ប្រធានគណៈមេធាវី**

មេធាវី លី-ច័ន្ទតុលា

***ចម្លងជូន:***

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជ្រាប"

-ឯកសារ-កាលប្បវត្តិ